


Asian International Justice Initiative (AIJI), a project of East-West Center and the WSD HANDA Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ៧៣

អង្គជំនុំជម្រះសាលាដំបូង បានចាប់ផ្តើមសប្តាហ៍នេះ ដោយធ្វើសវនាការឆ្លើយតបរវាងភាគីសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទលោក **ខៀវ សំផន** ទៅលើឯកសារគន្លឹះដែលបានដាក់បង្ហាញកាលពីសប្តាហ៍មុន ទាក់ទងទៅនឹងលក្ខណៈនៃជម្លោះប្រដាប់អាវុធ។[1] បន្ទាប់មក សក្ខីកម្មរបស់សាក្សី **2-TCW-1065** ដែលបន្តកាលពីសប្តាហ៍មុន ក៏ត្រូវបានធ្វើឡើងផងដែរ ពាក់ព័ន្ធនឹងជម្លោះនៅភូមិភាគបូព៌ា។ បន្ទាប់មកទៀត អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី លោក **ស សារិន** ដែលជាអ្នកផ្តល់សក្ខីកម្មដំបូងគេ ស្តីពីតួនាទីរបស់ជនជាប់ចោទ។ លោក **ស សារិន** ធ្លាប់បានផ្តល់សក្ខីកម្មក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង០០២ វគ្គ១ រួចម្តងហើយ ទោះជាយ៉ាងណានេះក្តី នៅកាលនោះ សក្ខីកម្មរបស់គាត់ត្រូវបានបញ្ឈប់ភ្លាមៗ នៅក្រោយពេលដែលគាត់បានបដិសេធមិនព្រមបន្តផ្តល់សក្ខីកម្ម ក្រោមហេតុផលថា គាត់មានភ័យខ្លាចពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់គាត់។[2] នៅក្នុងសប្តាហ៍នេះ គាត់ពុំបានវិលត្រឡប់មកផ្តល់សក្ខីកម្មនៅ

[1] ការដាក់បង្ហាញឯកសារគន្លឹះ ត្រូវបានរៀបចំឡើងកាលពីសប្តាហ៍មុន និងត្រូវបានសង្ខេបក្នុងរបាយការណ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម ក្នុងសំណុំរឿង០០២ វគ្គ២ លេខ៧២ ស្តីពីសវនាការលើកស្តុតាង សប្តាហ៍ទី៦៩ (ចុះថ្ងៃទី៣១ ខែតុលា ដល់ទី៣ ខែវិច្ឆិកា ឆ្នាំ២០១៦)។

[2] លោក **ស សារិន** ត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្ម ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង០០២ វគ្គ១ នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣ ក៏ប៉ុន្តែ គាត់ត្រូវបានលើកលែងដោយអង្គជំនុំជម្រះ នៅក្រោយពេលដែលគាត់បានបង្ហាញពីការភ័យខ្លាចដល់អាយុជីវិតរបស់គាត់ ហើយស្នើសុំឲ្យមានការផ្តល់នូវកងសន្តិសុខផ្ទាល់ខ្លួនសម្រាប់ការពារអាយុជីវិតរបស់គាត់ ឬក៏ស្នើសុំឲ្យមានការផ្លាស់ទីលំនៅរបស់គាត់ទៅនៅប្រទេសលោកខាងលិច។ អង្គជំនុំជម្រះបានយល់ឃើញថា អង្គជំនុំជម្រះខ្លួនឯងមិនមានយុត្តាធិការក្នុងការផ្តល់នូវវិធាន

ចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃព្រហស្បតិ៍ ដើម្បីបញ្ចប់សក្ខីកម្មរបស់គាត់នោះទេ ដោយយោងលើមូលហេតុដំបូងថា មកពីបញ្ហាសុខភាព ហើយបន្ទាប់មកទៀត គាត់ពុំបានលើឆ្លើយតបនឹងការទាក់ទងតាមទូរសព្ទពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ (WESU) នោះឡើយ។ ដូច្នេះហើយ បន្ទាប់ពីមានការឈប់សម្រាកនៅថ្ងៃពុធដើម្បីប្រារព្ធពិធីបុណ្យឯករាជ្យជាតិនៃព្រះរាជាណាចក្រកម្ពុជារួចមក អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មសាក្សីបន្ទាប់ចំនួនពីររូប ដែលត្រូវបានរៀបចំកាលវិភាគមកផ្តល់សក្ខីកម្មលើប្រធានបទនេះ គឺសាក្សីដែលប្រើប្រាស់អត្តលេខ 2-TCW-913 និង 2-TCCP-235 តែទោះជាយ៉ាងនេះក្តី ក៏អ្នកទាំងពីរពុំមានការយល់ដឹងច្រើនអំពីតួនាទីរបស់ជនជាប់ចោទនោះឡើយ។ កាលដើមឡើយ កាលវិភាគសវនាការ ត្រូវបានរៀបការស្តាប់សក្ខីកម្មរបស់គាត់នៅសប្តាហ៍នេះ ក៏ប៉ុន្តែ ដោយសារតែមានការផ្សព្វផ្សាយយឺតយ៉ាវអំពីសេចក្តីថ្លែងការណ៍មុនៗរបស់គាត់ សក្ខីកម្មរបស់សាក្សីដែលមានអត្តលេខ 2-TCW-953 ត្រូវបានពន្យារពេលរហូតដល់មួយសប្តាហ៍ បន្ទាប់ពីការឈប់សម្រាកមួយសប្តាហ៍ សម្រាប់ការប្រារព្ធពីធីអុំទូកអកអំបុកសំពះព្រះខែ។ កិច្ចដំណើរការនីតិវិធីសវនាការលើសំណុំរឿង០០២ វគ្គ២ នឹងត្រូវចាប់ផ្តើមឡើងវិញនៅថ្ងៃចន្ទ ទី២១ ខែវិច្ឆិកា នៅមុនពេលនៃការប្រកាសសាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២ វគ្គ១ ដែលគ្រោងធ្វើឡើងនៅថ្ងៃទី២៣ ខែវិច្ឆិកា នេះ។

---

* របាយការណ៍នេះ ត្រូវបានសរសេរដោយ ម៉ាយខល ចេន (Michael Chen), ហាន់ណា ដេយឆ៍ (Hanna Daych), ម៉ាលេនី ហៃដ៏ (Melanie Hyde), ខេតលីន កាហ្វហ្រៀ (Caitlin McCaffrie), និន វុទ្ធី, លូវីស រេតវ៉ាយលើ (Louise Rettweiler), តាយលីណា, ធំ ស្ថាពរ និង ភីនីឡូភី វ៉ាន់ធូល (Penelope Van Tuyl) ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោង ផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌលដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (The WSD HANDA Center) ដែលកាលពីមុនត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University

---

ការណ៍នេះឲ្យដើមបណ្តឹងរដ្ឋប្បវេណីរូបនេះឡើយ ហើយក៏មិនអាចបង្ខំគាត់ឲ្យផ្តល់សក្ខីកម្មផងដែរ។ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៣ ការិយាល័យសហព្រះរាជអាជ្ញា បានស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការពិចារណាឡើងវិញចំពោះសេចក្តីសម្រេចរបស់ខ្លួន ក៏ប៉ុន្តែអង្គជំនុំជម្រះមិនបានផ្លាស់ប្តូរគោលជំហរនេះឡើយ។ សម្រាប់សេចក្តីសង្ខេប ស្តីពីការផ្តល់សក្ខីកម្មដ៏ខ្លីរបស់គាត់ និងការពិភាក្សាជាបន្តបន្ទាប់ពីការបង្ហាញខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ សូមមើល របាយការណ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម ក្នុងសំណុំរឿង ០០២ វគ្គ១ លេខ៥៨ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី៥៣ (ចុះថ្ងៃទី២៩ មេសា ដល់៣ ឧសភា ឆ្នាំ២០១៣) ទំព័រ ១ ដល់៩ និង របាយការណ៍លេខ ៦៩ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី៦៤ (ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣) ទំព័រ ២។